ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១២៣ MIH / 2015

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី មាត្រាសាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញប្រកាសលេខ ៤១៥ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យ ផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញាទំនិញផលិត និងទំនិញវេចខ្ចប់

-បានឃើញប្រកាសលេខ ៤១២ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ ឧបករណ៍មាត្រាសាស្ត្រ

-បានឃើញប្រកាសលេខ ៤១៣ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យ ផ្ទៀងផ្ទាត់ជញ្ជីងមិនស្វ័យប្រវត្តិ

-យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១..**

ត្រូវបានធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

ក- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ៖

- ជញ្ជីងមិនស្វ័យប្រវត្តិ ដែលមានសមត្ថភាពត្រឹម១០០០(មួយពាន់)គីឡូក្រាមចុះក្រោម
- ជញ្ជីងសម្រាប់ថ្លឹងវត្ថុមានតម្លៃ ដូចជា មាស ប្រាក់ ប្លាទីន ត្បូងពេជ្រ...
- ដៃបាញ់ប្រេងនៅតាមស្ថានីយ៍ ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈ និងឧស្ម័ន
- ឧបករណ៍វាស់ប្រេងឥន្ធនៈ ដែលប្រើកែវក្រិតវ៉ែ។

ខ- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់ ដែលបានផលិត និងចរាចរនៅលើទីផ្សារក្នុងភូមិសាស្ត្រ រាជធានី ខេត្ត។

**ប្រការ២.-**

មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត មានភារកិច្ចអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ព្រមទាំងលក្ខខណ្ឌ និងបទដ្ឋានបច្ចេកទេស ដែលបានកំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយត្រូវមានកាតព្វកិច្ចធ្វើរបាយការណ៍ជូនមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិតាមការតម្រូវ។

**ប្រការ៣.-**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានសិទ្ធិចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការបំពេញមុខងារដែលបានធ្វើប្រតិភូកម្មជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដូចមានចែងក្នុងប្រការ១ ខាងលើ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ